មើលវីដេអូ ភាគទី ១៣

# សោភណចេតសិក ២៥

**សោភណចេតសិក** ជាចេតសិកផ្នែកល្អ មិនប្រកបជាមួយនឹង អកុសលចិត្ត ១២ និងអហេតុកចិត្ត ១៨ ទេ គឺប្រកបតែជាមួយនឹង ចិត្ត ៥៩ ឬ ៩១ ប៉ុណ្ណោះ។

**សោភណចេតសិកចែកចេញជា ៤ ន័យ គឺ៖**

១ - សោភណសាធារណចេតសិក ១៩

២ - វិរតិចេតសិក ៣

៣ - អប្បមញ្ញាចេតសិក ២

៤ - បញ្ញាចេតសិក ១

ស្កេនដើម្បីមើលមេរៀន
San Sochea Official

# អធិប្បាយ សោភណសាធារណចេតសិក ១៩

## ១ - សទ្ធាចេតសិក (Well-established confidence)

សទ្ទហតីតិ សទ្ធា ពុទ្ធាទីសុ បសាទោ ធម្មជាតិណា រមែងជឿជាក់ តែងជ្រះថ្លា (ឬទ្រទ្រង់អារម្មណ៍ទុកដោយល្អ) ព្រោះហេតុនោះ ធម្មជាតិនោះ ឈ្មោះថា សទ្ធា បានដល់សេចក្ដីជ្រះថ្លាក្នុងព្រះពុទ្ធជាដើម។

សទ្ធា បានដល់ការជឿជាក់ ឬសេចក្ដីជ្រះថ្លាក្នុងព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ កម្ម ផលរបស់កម្ម និងសេចក្ដីថាសត្វមានកម្មជារបស់ខ្លួន។

# លោកសន្និវាស មានប្រមាណ ៤ ៖

| | |
|---|---|
| ១ - រូបប្បមាណោ | អ្នកកាន់យករូបជាប្រមាណ |
| ២ - ឃោសប្បមាណោ | អ្នកកាន់យកសំឡេងជាប្រមាណ |
| ៣ - លូខប្បមាណោ | អ្នកកាន់យកភាពសៅហ្មងជាប្រមាណ |
| ៤ - ធម្មប្បមាណោ | អ្នកកាន់យកធម៌ជាប្រមាណ។ |

# លក្ខណាទិចតុក្កៈរបស់សទ្ធា

| | |
|---|---|
| ១ - សទ្ទហនលក្ខណា | មានការជឿជាក់ ជាលក្ខណៈ |
| ឱកប្បនលក្ខណា វា | ឫមានការមុតមាំ ជាលក្ខណៈ |
| សម្បក្ខន្ទនលក្ខណា វា | ឫមានការស្ទុះទៅ ជាលក្ខណៈ |
| ២ - សម្បសាទនរសា | មានការធ្វើឲ្យផូរផង់ (ជ្រះថ្លា) ជាកិច្ច ដូចកែវមណីធ្វើទឹកឲ្យថ្លា |
| ៣ - អកាលុស្សិយបច្ចុប្បដ្ឋានា | មានការមិនល្អក់កករ ជាអាការប្រាកដ |
| ៤ - សទ្ទេយ្យវត្ថុបទដ្ឋានា | មានវត្ថុជាទីតាំងនៃសេចក្តីជឿជាក់ជាហេតុជិត។ |

# ចំណាំ

*សទ្ធា ដូចជាដៃ ក្នុងការកាន់យកនូវកុសលទាំងឡាយ ដូចពុទ្ធវចនៈនៅក្នុងមហាវគ្គថា អបារុតា តេ អមតស្ស ទ្វារា យេ សោតវន្តោ បមុញ្ចន្តុ សទ្ធំ ទ្វារនៃព្រះនិព្វាននោះបើកហើយ សត្វទាំងឡាយណាមានសោតបសាទ សត្វទាំងឡាយនោះចូរបញ្ចេញនូវសទ្ធាចុះ។

*សទ្ធា ដូចជាទ្រព្យ ក្នុងការញុំាងសម្បត្តិទាំងឡាយឲ្យដល់ព្រម ដូចព្រះបរមគ្រូទ្រង់ត្រាស់ថា សទ្ធីធ វិត្តំ បុរិសស្ស សេដ្ឋំ សទ្ធាជាទ្រព្យដ៏ប្រសើររបស់បុរសក្នុងលោក។

*សទ្ធា ដូចជាពូជ ក្នុងការបានគ្រាប់កសិផលជាអមតៈ ព្រោះហេតុនោះព្រះបរមគ្រូទ្រង់ត្រាស់ថា សទ្ធា ពីជំ តបោ វុដ្ឋិ សទ្ធាដូចគ្រាប់ពូជ តបៈដូចទឹកភ្លៀង។



# សទ្ធា ពីរ យ៉ាង



**ចលសទ្ធា** សទ្ធានៅកម្រើក ឬញាប់ញ័រ (សទ្ធារបស់បុថុជ្ជន)

**អចលសទ្ធា** ឬ **សុបតិដ្ឋិតសទ្ធា** សទ្ធាមិនកម្រើក ឬតាំងមាំស៊ប់ (សទ្ធារបស់ព្រះអរិយៈ)